# កិច្ចព្រមព្រៀងទីក្រុងឡាអេស្តីពីការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្មចុះថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ១៩២៥

## ច្បាប់ទីក្រុងឡាអេចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៦០

## មាតិកា


មាត្រា ១ : ការបង្កើតសហភាព

មាត្រា ២ : និយមន័យ

មាត្រា ៣ : សិទ្ធិក្នុងការតម្កល់ជាអន្តរជាតិ

មាត្រា ៤ : ការតម្កល់នៅការិយាល័យអន្តរជាតិ ឬតាមរយៈការិយាល័យជាតិ

មាត្រា ៥ : ទម្រង់នៃការតម្កល់ ខ្លឹមសារនៃសំណុំលិខិតស្នើសុំ

មាត្រា ៦ : បញ្ជីគំនូរអន្តរជាតិ កាលបរិច្ឆេទនៃការចុះបញ្ជី ការចុះផ្សាយ ការពន្យារការចុះផ្សាយ ការប្រើប្រាស់បណ្ណសារដ្ឋានជាសាធារណៈ

មាត្រា ៧ : អានុភាពផ្លូវច្បាប់នៃការតម្កល់ដែលបានចុះបញ្ជី

មាត្រា ៨ : ការបដិសេធអានុភាពផ្លូវច្បាប់ដោយការិយាល័យជាតិ វិធានការដោះស្រាយទល់នឹងការបដិសេធ លក្ខខណ្ឌបន្ថែមដែលអាចមានដើម្បីឱ្យស្របតាមការិយាល័យជាតិ

មាត្រា ៩ : សិទ្ធិអាទិភាព

មាត្រា ១០ : ការចុះបញ្ជីតម្កល់សារឡើងវិញ

មាត្រា ១១ : រយៈពេលនៃកិច្ចការពារ

មាត្រា ១២ : ការប្តូរម្ចាស់កម្មសិទ្ធិ

មាត្រា ១៣ : ការបោះបង់ការតម្កល់

មាត្រា ១៤: សញ្ញាសម្គាល់ កំណត់សម្គាល់គំនូរអន្តរជាតិ

មាត្រា ១៥ : កម្រៃ

មាត្រា ១៦ : កម្រៃដែលជាកម្មសិទ្ធិរបស់រដ្ឋហត្ថលេខី

មាត្រា ១៧ : បទបញ្ជា

មាត្រា ១៨ : ការអនុវត្តន៍កិច្ចការពារដែលបានផ្តល់ឱ្យដោយច្បាប់ជាតិ និងដោយសន្ធិសញ្ញា

ស្តីពីសិទ្ធិអ្នកនិពន្ធ
មាត្រា ១៩ : [ និរាករណ៍ ]
មាត្រា ២០ : [ និរាករណ៍ ]
មាត្រា ២១ : [ និរាករណ៍ ]
មាត្រា ២២ : [ និរាករណ៍ ]
មាត្រា ២៣ : ហត្ថលេខា ការផ្តល់សច្ចាប័ន
មាត្រា ២៤ : ការចូលជាសមាជិក
មាត្រា ២៥ : ការអនុវត្តន៍កិច្ចព្រមព្រៀងតាមច្បាប់ជាតិ
មាត្រា ២៦ : ការចូលជាធរមាន
មាត្រា ២៧ : ដែនដី
មាត្រា ២៨ : ការប្រកាសដកខ្លួនចេញ
មាត្រា ២៩ : ការកែប្រែ
មាត្រា ៣០ : ក្រុមតាមតំបន់
មាត្រា ៣១ : ភាពអាចអនុវត្តបាននៃច្បាប់ឆ្នាំ ១៩២៥ ឬ ច្បាប់ឆ្នាំ ១៩៣៤
មាត្រា ៣២ : ពិធីសារឧបសម្ព័ន្ធ
មាត្រា ៣៣ : ហត្ថលេខា ច្បាប់ចម្លងដែលបានបញ្ជាក់

**ពិធីសារៈ** លទ្ធភាពនៃការអនុវត្តន៍ច្បាប់ឆ្នាំ១៩៦០ ដោយរដ្ឋហត្ថលេខីចំពោះការតម្កល់ជាអន្តរជាតិដែលមានប្រភពដើមនៅក្នុងរដ្ឋនេះ ។

## មាត្រា១

១- រដ្ឋហត្ថលេខីទាំងអស់រួមគ្នាបង្កើតជាសហភាពពិសេសមួយ ដើម្បីការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ។
២- មានតែរដ្ឋសមាជិកនៃសហភាពអន្តរជាតិដើម្បីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មប៉ុណ្ណោះដែលអាចក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា២

ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះៈ

“ កិច្ចព្រមព្រៀងឆ្នាំ ១៩២៥ ” សំដៅលើកិច្ចព្រមព្រៀងទីក្រុងឡាអេស្តីពី ការតម្កល់ជាអន្តរជាតិនូវគំនូរឧស្សាហកម្មចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩២៥ ។

“ កិច្ចព្រមព្រៀងឆ្នាំ ១៩៣៤ ” សំដៅលើកិច្ចព្រមព្រៀងទីក្រុងឡាអេ ស្តីពីការតម្កល់ជាអន្តរជាតិនូវគំនូរឧស្សាហកម្មចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩២៥ ដែលបានកែប្រែនៅទីក្រុងឡុងដ៍នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៣៤ ។

“ កិច្ចព្រមព្រៀងនេះ ” ឬ “ កិច្ចព្រមព្រៀងបច្ចុប្បន្ន ” សំដៅលើកិច្ចព្រមព្រៀងទីក្រុងឡាអេស្តីពីការតម្កល់ជាអន្តរជាតិនូវគំនូរឧស្សាហកម្មដែលបានបង្កើតដោយច្បាប់នេះ ។

“ បទបញ្ជា ” សំដៅលើបទបញ្ជាដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

“ ការិយាល័យអន្តរជាតិ ” សំដៅលើការិយាល័យអន្តរជាតិកម្មសិទ្ធិបញ្ញា ។

“ ការតម្កល់ជាអន្តរជាតិ ”សំដៅលើការតម្កល់ដែលបានធ្វើឡើងនៅការិយាល័យអន្តរជាតិ ។

“ ការតម្កល់ថ្នាក់ជាតិ ” សំដៅលើការតម្កល់ដែលបានធ្វើឡើងនៅការិយាល័យជាតិរបស់រដ្ឋហត្ថលេខី ។

“ ការតម្កល់ច្រើន ” សំដៅលើការតម្កល់ដែលរួមមានគំនូរមួយចំនួន ។

“ រដ្ឋដើមនៃការតម្កល់ជាអន្តរជាតិ ” សំដៅលើរដ្ឋហត្ថលេខីដែលអ្នកដាក់ពាក្យសុំមានគ្រឹះស្ថានពាណិជ្ជកម្ម ឬឧស្សាហកម្មពិតនិងកំពុងដំណើរការ ឬ សំដៅរដ្ឋហត្ថលេខីដែលអ្នកដាក់ពាក្យសុំបានបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំរបស់ខ្លួន ប្រសិនបើអ្នកដាក់ពាក្យសុំនេះមានគ្រឹះស្ថាននៅក្នុងរដ្ឋហត្ថលេខីមួយចំនួន ។ ប្រសិនបើអ្នកដាក់ពាក្យសុំគ្មានគ្រឹះស្ថាននៅក្នុងរដ្ឋហត្ថលេខីណាមួយទេ សំដៅដល់រដ្ឋហត្ថលេខីដែលអ្នកដាក់ពាក្យសុំមានលំនៅឋាន ។ ប្រសិនបើអ្នកដាក់ពាក្យសុំគ្មានលំនៅឋាននៅក្នុងរដ្ឋហត្ថលេខីទេ សំដៅដល់រដ្ឋហត្ថលេខីដែលអ្នកដាក់ពាក្យសុំគឺជាពលរដ្ឋនៃរដ្ឋនោះ ។

“ រដ្ឋដែលមានការត្រួតពិនិត្យភាពថ្មី ” សំដៅទៅលើរដ្ឋហត្ថលេខីដែលច្បាប់ជាតិរបស់រដ្ឋនោះចែងឱ្យមាន ប្រព័ន្ធមួយដែលពាក់ព័ន្ធនឹងការស្រាវជ្រាវជាបឋមដោយខ្លួនឯង និងការត្រួតពិនិត្យដោយការិយាល័យជាតិរបស់ខ្លួនចំពោះភាពថ្មីនៃគំនូរនីមួយៗដែលបានតម្កល់ ។

## មាត្រា៣

ពលរដ្ឋរបស់រដ្ឋហត្ថលេខី និងបុគ្គលទាំងឡាយដែលពុំមែនជាពលរដ្ឋនៃរដ្ឋហត្ថលេខីណាមួយ ដែលមានលំនៅឋាន ឬមានគ្រឹះស្ថានពាណិជ្ជកម្ម ឬឧស្សាហកម្មពិត និងកំពុងដំណើរការនៅក្នុងដែនដីនៃរដ្ឋហត្ថលេខី អាចតម្កល់គំនូរនៅការិយាល័យអន្តរជាតិបាន ។

## មាត្រា៤

១- ការតម្កល់ជាអន្តរជាតិអាចធ្វើឡើងនៅការិយាល័យអន្តរជាតិ:

១. ដោយផ្ទាល់ ឬ

២. តាមរយៈការិយាល័យជាតិរបស់រដ្ឋហត្ថលេខីមួយ ប្រសិនបើច្បាប់នៃរដ្ឋនោះអនុញ្ញាតឱ្យធ្វើបែបនេះ ។

២- ច្បាប់ជាតិនៃរដ្ឋហត្ថលេខីណាមួយ អាចតម្រូវឱ្យការតម្កល់ជាអន្តរជាតិដែលរដ្ឋហត្ថលេខីត្រូវបានចាត់ទុកជារដ្ឋដើម ត្រូវធ្វើតាមរយៈការិយាល័យជាតិរបស់ខ្លួន ។ ការមិនគោរពតាមលក្ខខណ្ឌនេះនឹងមិនប៉ះពាល់ដល់អានុភាព នៃការតម្កល់ជាអន្តរជាតិនៅក្នុងរដ្ឋហត្ថលេខីផ្សេងទៀតទេ ។

## មាត្រា៥

១- ការតម្កល់ជាអន្តរជាតិត្រូវរួមមាននូវសំណុំលិខិតស្នើសុំមួយ និងរូបថតមួយឬច្រើន ឬគំនូសតាងផ្សេងទៀតជាតំណាងនៃគំនូរ ហើយត្រូវរួមបញ្ចូលទាំងការបង់កម្រៃដែលបានកំណត់ដោយបទបញ្ជា ។

២- សំណុំលិខិតស្នើសុំត្រូវរួមមាន:

១. បញ្ជីនៃរដ្ឋហត្ថលេខី ដែលអ្នកដាក់ពាក្យសុំស្នើសុំឱ្យការតម្កល់ជាអន្តរជាតិត្រូវមានអានុភាពក្នុងរដ្ឋនេះ

២. ការជ្រើសរើសវត្ថុមួយ ឬច្រើន ដែលគេមានបំណងនឹងបញ្ចូលគំនូរទៅក្នុងវត្ថុនោះ

៣. ការបញ្ជាក់កាលបរិច្ឆេទ រដ្ឋ និងចំនួននៃការតម្កល់ដែលបង្កើតសិទ្ធិអាទិភាព ប្រសិនបើអ្នកដាក់ពាក្យសុំមានបំណងទាមទារអាទិភាពដូចមានចែងក្នុងមាត្រា៩

៤. ចំនុចពិសេសផ្សេងទៀតដូចមានប្បញ្ញត្តិក្នុងបទបញ្ជា ។

៣-

ក- ក្រៅពីនេះ សំណុំលិខិតស្នើសុំអាចរួមមានៈ

១. សេចក្តីអធិប្បាយខ្លីមួយ អំពីលក្ខណៈរូបរាងនៃគំនូរ

២. សេចក្តីប្រកាស អំពីអ្នកបង្កើតស្នាដៃពិតនៃគំនូរ

៣. ពាក្យសុំពន្យារការធ្វើការចុះផ្សាយដូចមានចែងក្នុងមាត្រា៦(៤) ។

ខ- សំណុំលិខិតស្នើសុំក៏អាចអមមកជាមួយផងដែរដោយសំណាក ឬគំរូ នៃវត្ថុមួយ ឬច្រើន ដែលមានគំនូរនេះ ។

៤- ការតម្កល់ច្រើន អាចបញ្ចូលនូវគំនូរមួយចំនួន ដែលគេមានបំណងនឹងដាក់បញ្ចូលទៅក្នុងវត្ថុ ដែលស្ថិតនៅក្នុងក្រុមជាមួយគ្នានៃចំណាត់ថ្នាក់គំនូរអន្តរជាតិ ដូចមានចែងក្នុងមាត្រា ២១(២) ចំនុច ៤ ។

## មាត្រា៦

១- ការិយាល័យអន្តរជាតិត្រូវរក្សាបញ្ជីគំនូរអន្តរជាតិ និងត្រូវចុះបញ្ជីការតម្កល់ជាអន្តរជាតិក្នុងបញ្ជីគំនូរអន្តរជាតិនេះ។

២- ការតម្កល់ជាអន្តរជាតិត្រូវចាត់ទុកថាបានធ្វើឡើង តាមកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិទទួលបានសំណុំលិខិតស្នើសុំក្នុងទម្រង់ត្រឹមត្រូវ ទទួលបានកម្រៃដែលបានបង់ជាមួយសំណុំលិខិតស្នើសុំ ព្រមទាំងរូបថតមួយឬច្រើន ឬគំនូសតាងផ្សេងទៀតជាតំណាងនៃគំនូរ ឬចាត់ទុកថាបានធ្វើឡើងនៅកាលបរិច្ឆេទចុងក្រោយទាំងនេះ ប្រសិនបើការិយាល័យអន្តរជាតិបានទទួលនូវឯកសារទាំងនេះ នៅកាលបរិច្ឆេទខុសៗពីគ្នា ។ ការចុះបញ្ជីត្រូវមានកាលបរិច្ឆេទតែមួយ ។

៣-

ក- ចំពោះការតម្កល់ជាអន្តរជាតិនីមួយៗ ការិយាល័យអន្តរជាតិត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រនូវៈ

១. ការផលិតឡើងវិញជា ស ខ្មៅ ឬតាមសំណើរបស់អ្នកដាក់ពាក្យសុំជាពណ៌ធម្មជាតិនៃរូបថត ឬ គំនូសតាងផ្សេងទៀតដែលបានតម្កល់

២. កាលបរិច្ឆេទនៃការតម្កល់ជាអន្តរជាតិ

៣. ចំនុចពិសេសផ្សេងទៀត ដែលបានកំណត់ដោយបទបញ្ជា ។

ខ- ការិយាល័យអន្តរជាតិត្រូវផ្ញើព្រឹត្តិបត្រទៅកាន់ការិយាល័យជាតិឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។

៤-

ក- តាមសំណើរបស់អ្នកដាក់ពាក្យសុំ ការចុះផ្សាយដូចមានចែងក្នុងកថាខណ្ឌ(៣)(ក) ត្រូវតែពន្យារក្នុងរយៈពេលដែលអ្នកដាក់ពាក្យសុំបានស្នើសុំ ។ រយៈពេលខាងលើនេះមិនអាចលើសពី១២(ដប់ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់ជាអន្តរជាតិឡើយ ។ ប៉ុន្តែ ប្រសិនបើមានការទាមទារអាទិភាព កាលបរិច្ឆេទចាប់ផ្តើមនៃរយៈពេលនេះនឹងត្រូវជាកាលបរិច្ឆេទអាទិភាព ។

ខ- នៅពេលណាក៏បាននៃរយៈពេលដូចមានចែងក្នុងអនុកថាខណ្ឌ(ក) អ្នកដាក់ពាក្យសុំអាចសុំឱ្យធ្វើការចុះផ្សាយភ្លាម ឬអាចដកការតម្កល់របស់ខ្លួនទៅវិញ ។ ការដកការតម្កល់អាចកម្រិតត្រឹមតែរដ្ឋហត្ថលេខីមួយឬមួយចំនួនតែប៉ុណ្ណោះ ហើយក្នុងករណីដែលមានការតម្កល់ច្រើន ត្រូវកម្រិតត្រឹមតែគំនូរមួយចំនួនដែលបានបញ្ចូលក្នុងការតម្កល់នេះប៉ុណ្ណោះក្នុងករណីដែលមានការតម្កល់ច្រើន។

គ- ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់កម្រៃ ដែលត្រូវបង់ក្នុងរយៈពេលត្រឹមត្រូវមុនការផុតពេលរយៈពេលដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ការិយាល័យអន្តរជាតិត្រូវបដិសេធនូវការតម្កល់ និង មិនត្រូវធ្វើការចុះផ្សាយដូចមានចែងក្នុងកថាខណ្ឌ(៣)(ក) ឡើយ ។

ឃ- រហូតដល់ការផុតកំណត់រយៈពេលដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ការិយាល័យអន្តរជាតិត្រូវរក្សាការសំងាត់អំពីការចុះបញ្ជីតម្កល់ដែលបានធ្វើឡើង យោងតាមការពន្យារការចុះផ្សាយ ហើយសាធារណជនគ្មានសិទ្ធិទទួលបានឯកសារ ឬ វត្ថុណាមួយដែលពាក់ព័ន្ធនឹងការតម្កល់នោះទេ ។ បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តដោយគ្មានការកំណត់រយៈពេល ប្រសិនបើអ្នកដាក់ពាក្យសុំបានដកការតម្កល់របស់ខ្លួន មុនការផុតកំណត់រយៈដូចបានលើកឡើងខាងលើ ។

៥- លើកលែងតែមានចែងក្នុងកថាខណ្ឌ(៤) បញ្ជី ព្រមទាំងឯកសារទាំងអស់ និងវត្ថុទាំងឡាយដែលបានដាក់នៅការិយាល័យអន្តរជាតិ ត្រូវបើកឱ្យសាធារណជនបានពិនិត្យ ។

## មាត្រា៧

១-

ក- ការតម្កល់ដែលបានចុះបញ្ជីនៅការិយាល័យអន្តរជាតិត្រូវមានអានុភាពដូចៗគ្នានៅក្នុងរដ្ឋហត្ថលេខីនីមួយៗ ដែលបានជ្រើសរើសដោយអ្នកដាក់ពាក្យសុំក្នុងសំណុំលិខិតស្នើសុំរបស់ខ្លួន ប្រសិនបើគ្រប់ទម្រង់ដែលបានទាមទារដោយច្បាប់ជាតិដើម្បីផ្តល់កិច្ចការ

៣រ បានអនុវត្តតាមដោយអ្នកដាក់ពាក្យសុំ ហើយប្រសិនបើគ្រប់លិខិតរដ្ឋបាលទាំងអស់ដែលបានទាមទារក្នុងរឿងនេះត្រូវបានបំពេញដោយការិយាល័យនៃរដ្ឋនេះ។

ខ- លើកលែងបទប្បញ្ញត្តិនៃមាត្រា១១ កិច្ចការពារគំនូរដែលបានចុះបញ្ជីតម្កល់នៅការិយាល័យអន្តរជាតិត្រូវបានគ្រប់គ្រងនៅក្នុងរដ្ឋហត្ថលេខីនីមួយៗ ដោយបទប្បញ្ញត្តិទាំងឡាយ នៃច្បាប់ជាតិដែលអនុវត្តនៅក្នុងរដ្ឋនោះចំពោះគំនូរដែលកិច្ចការពារត្រូវបានទាមទារដោយឈរលើមូលដ្ឋាននៃការតម្កល់ថ្នាក់ជាតិ និងនៅពេលទម្រង់បែបបទ និងលិខិតរដ្ឋបាលទាំងអស់ត្រូវបានគោរពតាមនិងបំពេញចប់សព្វគ្រប់។

២- ការតម្កល់ជាអន្តរជាតិមិនត្រូវមានអានុភាពនៅក្នុងរដ្ឋដើមឡើយ ប្រសិនបើច្បាប់នៃរដ្ឋនោះចែងដូច្នេះ ។

## មាត្រា៨

១- ថ្វីបើមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា៧ក៏ដោយ ការិយាល័យជាតិនៃរដ្ឋហត្ថលេខីដែលច្បាប់ជាតិរបស់រដ្ឋនោះបានចែងថា ការិយាល័យជាតិអាចធ្វើការបដិសេធកិច្ចការពារបានដោយឈរលើមូលដ្ឋាននៃការត្រួតពិនិត្យខាងរដ្ឋបាលដោយខ្លួនឯង ឬតាមការបណ្តឹងជំទាស់ពីភាគីទីបី ក្នុងករណីមានការបដិសេធ ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិក្នុងរយៈពេល៦(ប្រាំមួយ)ខែថា គំនូរនោះមិនបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់ជាតិរបស់រដ្ឋហត្ថលេខីនោះទេ ក្រៅពីទម្រង់បែបបទនិងលិខិតរដ្ឋបាលដូចមានចែងក្នុងមាត្រា៧(១) ។ ប្រសិនបើមិនបានជូនដំណឹងអំពីការបដិសេធក្នុងរយៈពេល ៦(ប្រាំមួយ)ខែនោះទេ ការតម្កល់ជាអន្តរជាតិត្រូវមានអានុភាពនៅក្នុងរដ្ឋនោះចាប់ពីកាលបរិច្ឆេទនៃការតម្កល់ ។ ប៉ុន្តែ នៅក្នុងរដ្ឋហត្ថលេខីដែលមានការត្រួតពិនិត្យភាពថ្មី ការតម្កល់ជាអន្តរជាតិក្នុងរយៈពេលរក្សាអាទិភាព ត្រូវមានអានុភាពចាប់ពីការផុតកំណត់រយៈពេលខាងលើ លើកលែងតែច្បាប់ជាតិចែងពីកាលបរិច្ឆេទដំបូងចំពោះការតម្កល់ដែលបានធ្វើឡើងនៅការិយាល័យជាតិរបស់រដ្ឋហត្ថលេខី ប្រសិនបើមិនបានជូនដំណឹងអំពីការបដិសេធក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ។

២- រយៈពេល៦(ប្រាំមួយ)ខែដូចមានចែងក្នុងកថាខណ្ឌ(១) ត្រូវគិតចាប់ពីកាលបរិច្ឆេទដែលការិយាល័យជាតិទទួលបានការចេញផ្សាយព្រឹត្តិបត្រ ដែលមានបោះផ្សាយនូវការចុះបញ្ជីតម្កល់គំនូរជាអន្តរជាតិ ។ ការិយាល័យជាតិត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនេះទៅកាន់បុគ្គលណាមួយដែលបានស្នើសុំ ។

៣- អ្នកដាក់ពាក្យសុំត្រូវមានវិធានការដោះស្រាយដូចគ្នា ដើម្បីតទល់ទៅនឹងការបដិសេធរបស់ការិយាល័យជាតិដូចមានចែងក្នុងកថាខណ្ឌ(១) ប្រសិនបើអ្នកដាក់ពាក្យសុំនោះបានតម្កល់នូវគំនូររបស់ខ្លួនក្នុងការិយាល័យនោះ ។ ក្នុងករណីណាក៏ដោយ ការបដិសេធត្រូវជាកម្មវត្ថុនៃការស្នើសុំឱ្យត្រួតពិនិត្យឡើងវិញ ឬការប្ដឹងជំទាស់ ។ សេចក្ដីជូនដំណឹងអំពីការបដិសេធត្រូវបញ្ជាក់ពី:

១. មូលហេតុដែលបង្ហាញថា គំនូរនោះមិនបានបំពេញតាមលក្ខខណ្ឌរបស់ច្បាប់ជាតិ

២. កាលបរិច្ឆេទដូចមានចែងក្នុងកថាខណ្ឌ (២)

៣. រយៈពេលអនុញ្ញាតចំពោះសំណើសុំឱ្យត្រួតពិនិត្យឡើងវិញ ឬ ការបណ្ដឹងជំទាស់

៤. អាជ្ញាធរ ដែលទទួលសំណើសុំ ឬការបណ្ដឹងជំទាស់ ។

៤-

ក- ការិយាល័យជាតិរបស់រដ្ឋហត្ថលេខី ដែលច្បាប់ជាតិរបស់រដ្ឋនោះមាននូវបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌ(១) ដែលទាមទារនូវសេចក្ដីប្រកាសដើម្បីបញ្ជាក់ពីអ្នកបង្កើតស្នាដៃពិតនៃគំនូរ ឬទាមទារសេចក្ដីអធិប្បាយអំពីគំនូរ អាចចែងថា តាមសំណើសុំ និងក្នុងរយៈពេលមិនតិចជាង៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបញ្ជូនសំណើសុំដោយការិយាល័យខាងលើ អ្នកដាក់ពាក្យសុំត្រូវដាក់ជាភាសានៃសំណុំលិខិតស្នើសុំដែលបានដាក់ជាមួយការិយាល័យអន្តរជាតិនូវ:

១. សេចក្ដីប្រកាសបញ្ជាក់ពីអ្នកបង្កើតស្នាដៃពិតនៃគំនូរ ។

២. សេចក្ដីអធិប្បាយខ្លីមួយដែលបញ្ជាក់ពីលក្ខណៈរូបរាងសំខាន់នៃគំនូរដូចជាការបង្ហាញតាមរូបថត ឬគំនូសតាងជាតំណាងផ្សេងទៀត ។

ខ-ការិយាល័យជាតិមិនត្រូវយកថ្លៃចំពោះការដាក់សេចក្ដីប្រកាស ឬសេចក្ដីអធិប្បាយ ឬការចុះផ្សាយដោយការិយាល័យជាតិប្រសិនបើមាន ។

៥-

ក- រដ្ឋហត្ថលេខីណាមួយដែលច្បាប់ជាតិរបស់រដ្ឋនោះមានបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌ(១) ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីបញ្ហានេះ ។

ខ- តាមច្បាប់របស់ខ្លួន ប្រសិនបើរដ្ឋហត្ថលេខីមួយ មានប្រព័ន្ធមួយចំនួនដែលការពារគំនូរ ហើយបើមានមានប្រព័ន្ធមួយចែងពីការត្រួតពិនិត្យភាពថ្មី នោះបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដែលពាក់ព័ន្ធនឹងរដ្ឋដែលមានការត្រួតពិនិត្យភាពថ្មីនេះ ត្រូវអនុវត្តចំពោះតែប្រព័ន្ធនេះតែប៉ុណ្ណោះ ។

## មាត្រា៩

កាលបរិច្ឆេទអាទិភាព គឺជាកាលបរិច្ឆេទនៃការតម្កល់លើកដំបូង ប្រសិនបើការតម្កល់គំនូរជាអន្តរជាតិបានធ្វើឡើងក្នុងរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ការតម្កល់លើកដំបូងនៃគំនូរដូចគ្នានៅក្នុងរដ្ឋមួយ ដែលជាសមាជិកនៃសហភាពអន្តរជាតិទទួលបន្ទុកកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ហើយប្រសិនបើអាទិភាពត្រូវបានទាមទារ ចំពោះការតម្កល់ជាអន្តរជាតិ ។

## មាត្រា១០

១- ការតម្កល់ជាអន្តរជាតិអាចចុះបញ្ជីសារឡើងវិញបានជារៀងរាល់៥(ប្រាំ)ឆ្នាំ ដោយបង់តែកម្រៃចុះបញ្ជីសារឡើងវិញដូចមានកំណត់ក្នុងបទបញ្ជា ក្នុងឆ្នាំចុងក្រោយនៃរយៈពេលប្រាំឆ្នាំម្តង ។
២- បើមានការបង់កម្រៃបន្ថែមដែលបានកំណត់ដោយបទបញ្ជា ត្រូវផ្តល់រយៈពេលអនុគ្រោះ ៦(ប្រាំមួយ)ខែ ចំពោះការចុះបញ្ជីសារឡើងវិញនៃការតម្កល់ជាអន្តរជាតិ ។
៣- នៅពេលបង់កម្រៃចុះបញ្ជីសារឡើងវិញ ត្រូវបញ្ជាក់ពីចំនួននៃការតម្កល់ជាអន្តរជាតិ ហើយបញ្ជាក់ផងដែរនូវចំនួនរដ្ឋហត្ថលេខីដែលការចុះបញ្ជីសារឡើងវិញនឹងត្រូវធ្វើ ប្រសិនបើមិនបានធ្វើការចុះបញ្ជីសារឡើងវិញក្នុងរដ្ឋហត្ថលេខីទាំងអស់ ដែលការតម្កល់ជិតផុតកំណត់ ។
៤- ការចុះបញ្ជីសារឡើងវិញអាចត្រូវបានកម្រិតចំពោះតែគំនូរមួយចំនួន ដែលបានបញ្ចូលក្នុងការតម្កល់ច្រើន ។
៥- ការិយាល័យអន្តរជាតិត្រូវកត់ត្រា និងបោះពុម្ពផ្សាយការចុះបញ្ជីសារឡើងវិញ ។

## មាត្រា១១

១-

ក- រយៈពេលនៃកិច្ចការពារដែលបានផ្តល់ឱ្យដោយ រដ្ឋហត្ថលេខីចំពោះគំនូរដែលជាកម្មវត្ថុនៃការតម្កល់ជាអន្តរជាតិមិនត្រូវមានរយៈពេលតិចជាងៈ

១. ដប់ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការតម្កល់ជាអន្តរជាតិ ប្រសិនបើការតម្កល់នោះបានចុះបញ្ជីសារឡើងវិញ ។

២. ប្រាំឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់ជាអន្តរជាតិដោយគ្មានការចុះបញ្ជីសារឡើងវិញ។

ខ- ប៉ុន្តែ យោងតាមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់រដ្ឋហត្ថលេខីដែលមានការត្រួតពិនិត្យពីភាពថ្មី ប្រសិនបើកិច្ចការពារចាប់ផ្ដើមតាមកាលបរិច្ឆេទបន្ទាប់ពីការតម្កល់ជាអន្តរជាតិ រយៈពេលអប្បបរមាដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្ដើមការពារនៅក្នុងរដ្ឋនោះ ។ ការដែលថា ការតម្កល់ជាអន្តរជាតិមិនបានចុះបញ្ជីសារឡើងវិញ ឬបានចុះបញ្ជីសារឡើងវិញបានតែម្ដង វាមិនប៉ះពាល់ដល់រយៈពេលអប្បបរមានៃកិច្ចការពារដែលបានកំណត់នេះទេ ។

២- ចំពោះគំនូរដែលជាកម្មវត្ថុនៃការតម្កល់ថ្នាក់ជាតិ ប្រសិនបើច្បាប់ជាតិនៃរដ្ឋហត្ថលេខីចែងឱ្យការពារក្នុងរយៈពេលលើសពី១០(ដប់)ឆ្នាំ ទោះបីជាមានឬគ្មានការចុះបញ្ជីសារឡើងវិញក៏ដោយ ក៏ត្រូវផ្ដល់កិច្ចការពាររយៈពេលដូចគ្នា ក្នុងរដ្ឋនេះចំពោះគំនូរទាំងឡាយដែលជាកម្មវត្ថុនៃការតម្កល់ជាអន្តរជាតិ ដោយឈរលើមូលដ្ឋាននៃការតម្កល់ជាអន្តរជាតិនិងការចុះបញ្ជីសារឡើងវិញ ។

៣- តាមច្បាប់ជាតិរបស់ខ្លួន រដ្ឋហត្ថលេខីអាចកម្រិតរយៈពេលនៃកិច្ចការពារគំនូរដែលជាកម្មវត្ថុនៃការតម្កល់ជាអន្តរជាតិ ឱ្យដូចទៅនឹងរយៈពេលដែលមានចែងក្នុង កថាខណ្ឌ(១) ។

៤- លើកលែងបទប្បញ្ញត្តិនៃកថាខណ្ឌ(១)(ខ) កិច្ចការពារនៅក្នុងរដ្ឋហត្ថលេខី ត្រូវបញ្ចប់តាមកាលបរិច្ឆេទនៃការផុតកំណត់ការតម្កល់ជាអន្តរជាតិ លើកលែងតែច្បាប់ជាតិរបស់រដ្ឋនេះចែងឱ្យកិច្ចការពារត្រូវតែបន្ត បន្ទាប់ពីកាលបរិច្ឆេទនៃការផុតកំណត់ការតម្កល់ជាអន្តរជាតិ ។

## មាត្រា១២

១- ការិយាល័យអន្តរជាតិត្រូវកត់ត្រា និងបោះផ្សាយរាល់ការផ្លាស់ប្ដូរទាំងឡាយដែលពាក់ព័ន្ធនឹងម្ចាស់សិទ្ធិនៃគំនូរដែលជាកម្មវត្ថុនៃការតម្កល់ជាអន្តរជាតិដែលនៅជាធរមាន។ ត្រូវយល់ថា ការផ្ទេរម្ចាស់កម្មសិទ្ធិអាចកម្រិតចំពោះសិទ្ធិដែលកើតឡើងពីការតម្កល់ជាអន្តរជាតិនៅក្នុងរដ្ឋហត្ថលេខីមួយ ឬមួយចំនួនប៉ុណ្ណោះ ព្រមទាំងកម្រិតចំពោះតែគំនូរមួយចំនួនដែលបានបញ្ចូលក្នុងការតម្កល់ ក្នុងករណីនៃការតម្កល់ច្រើន ។

២- ការកត់ត្រាដូចមានចែងនៅក្នុងកថាខណ្ឌ(១) ត្រូវមានអានុភាពដូចគ្នាទៅនឹងការកត់ត្រាដែលបានធ្វើឡើងក្នុងការិយាល័យជាតិរបស់រដ្ឋហត្ថលេខី ។

## មាត្រា១៣

១- តាមរយៈសេចក្តីប្រកាសដែលបានធ្វើនៅការិយាល័យអន្តរជាតិ ម្ចាស់សិទ្ធិនៃការតម្កល់ជាអន្តរជាតិអាចបោះបង់សិទ្ធិរបស់ខ្លួន ចំពោះរដ្ឋហត្ថលេខីទាំងអស់ ឬតែចំពោះរដ្ឋហត្ថលេខីមួយចំនួន ព្រមទាំងចំពោះគំនូរមួយចំនួនដែលបានបញ្ចូលក្នុងការតម្កល់ ក្នុងករណីនៃការតម្កល់ច្រើន ។

២- ការិយាល័យអន្តរជាតិត្រូវកត់ត្រា និងបោះផ្សាយសេចក្តីប្រកាសនេះ ។

## មាត្រា១៤

១- ជាលក្ខខណ្ឌនៃការទទួលស្គាល់សិទ្ធិចំពោះកិច្ចការពារ គ្មានរដ្ឋហត្ថលេខីណាអាចទាមទារឱ្យវត្ថុដែលមានបញ្ចូលគំនូរ មានសញ្ញា ឬកំណត់សម្គាល់ពាក់ព័ន្ធនឹងការតម្កល់គំនូរនោះឡើយ។

២- ប្រសិនបើច្បាប់ជាតិនៃរដ្ឋហត្ថលេខីចែងអំពីកំណត់សម្គាល់លើវត្ថុ ក្នុងគោលបំណងផ្សេងទៀត រដ្ឋនេះត្រូវចាត់ទុកលក្ខខណ្ឌនេះថាបានបំពេញ ប្រសិនបើវត្ថុទាំងអស់ដែលដាក់ជូនសាធារណជនមានការអនុញ្ញាតពីម្ចាស់សិទ្ធិ ជាគំនូរ ឬស្លាកដែលភ្ជាប់នឹងវត្ថុនេះមានកំណត់សម្គាល់គំនូរអន្តរជាតិ ។

៣- កំណត់សម្គាល់គំនូរអន្តរជាតិត្រូវមាននិមិត្តសញ្ញា Ⓓ (អក្សរ D នៅក្នុងរង្វង់) ដែលភ្ជាប់មកដោយ:

១. ឆ្នាំនៃការតម្កល់អន្តរជាតិ និងឈ្មោះ ឬឈ្មោះកាត់ដែលប្រើជាទូទៅរបស់អ្នកតម្កល់ ឬ

២. លេខនៃការតម្កល់ជាអន្តរជាតិ ។

៤- គ្រាន់តែរូបភាពខាងក្រៅនៃកំណត់សម្គាល់គំនូរអន្តរជាតិលើវត្ថុ ឬលើស្លាកទាំងឡាយមិនត្រូវបានបកស្រាយថា ជាការបោះបង់កិច្ចការពារ តាមអត្ថន័យនៃសិទ្ធិអ្នកនិពន្ធ ឬ ដោយមូលហេតុផ្សេងទៀត ទោះជាគ្មានកំណត់សម្គាល់ក៏ដោយ កិច្ចការពារនេះអាចត្រូវទាមទារពេលណាក៏បាន ។

## មាត្រា១៥

១- កម្រៃដែលបានកំណត់ដោយបទបញ្ជាត្រូវរួមមាន:

១. កម្រៃសម្រាប់ការិយាល័យអន្តរជាតិ

២. កម្រៃសម្រាប់រដ្ឋហត្ថលេខីដែលបានជ្រើសរើសដោយអ្នកដាក់ពាក្យសុំ រួមមានៈ

(ក) កម្រៃសម្រាប់រដ្ឋហត្ថលេខីនីមួយៗ

(ខ) កម្រៃសម្រាប់រដ្ឋហត្ថលេខីនីមួយៗ ដែលមានការត្រួតពិនិត្យភាពថ្មី និងដែលទាមទារការបង់កម្រៃចំពោះការត្រួតពិនិត្យនេះ ។

២- កម្រៃណាមួយដែលបានបង់ចំពោះការតម្កល់តែមួយ និងដូចគ្នាសម្រាប់រដ្ឋហត្ថលេខី តាមកថាខណ្ឌ(១) ចំនុច២(ក) ត្រូវកាត់ចេញពីបរិមាណនៃកម្រៃដូចមានចែងក្នុងកថាខណ្ឌ (១) ចំនុច២(ខ) ប្រសិនបើកម្រៃក្នុងចំណុច២(ខ)អាចបង់ចំពោះរដ្ឋដូចគ្នា ។

## មាត្រា១៦

១- កម្រៃសម្រាប់រដ្ឋហត្ថលេខីដូចមានចែងក្នុងមាត្រា ១៥(១) ចំនុច២ ត្រូវប្រមូលដោយការិយាល័យអន្តរជាតិ និងត្រូវបង់ជារៀងរាល់ឆ្នាំដោយអ្នកដាក់ពាក្យសុំទៅឱ្យរដ្ឋហត្ថលេខីដែលបានជ្រើសរើស ដោយអ្នកដាក់ពាក្យសុំ។

២-

ក- រដ្ឋហត្ថលេខីណាមួយអាចជូនដំណឹងទៅការិយាល័យអន្តរជាតិថា ខ្លួនបោះបង់សិទ្ធិចំពោះកម្រៃបន្ថែមដូចមានចែងក្នុងមាត្រា១៥(១)ចំណុច២(ក) សម្រាប់ការតម្កល់ជាអន្តរជាតិ ដែលរដ្ឋហត្ថលេខីផ្សេងទៀតដែលបានបោះបង់ដូចគ្នានេះ ត្រូវបានចាត់ទុកថាជារដ្ឋដើម។

ខ- រដ្ឋនេះអាចបោះបង់ដូចគ្នាចំពោះការតម្កល់ជាអន្តរជាតិដែលរដ្ឋខ្លួនឯងត្រូវបានចាត់ទុកថាជារដ្ឋដើម ។

## មាត្រា១៧

បទបញ្ញាត្រូវកំណត់សេចក្តីលម្អិតពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះហើយជាពិសេសគឺ:

១. ភាសានិងចំនួននៃច្បាប់ចម្លង ដែលសំណុំលិខិតស្នើសុំចំពោះការតម្កល់ត្រូវដាក់ព្រមទាំងទិន្នន័យដែលត្រូវផ្តល់ក្នុងសំណុំលិខិតស្នើសុំ ។

២. ចំនួនទឹកប្រាក់ និងកាលបរិច្ឆេទ ព្រមទាំងរបៀបបង់កម្រៃចំពោះការិយាល័យអន្តរជាតិនិងរដ្ឋទាំងឡាយ រួមបញ្ចូលទាំងការកម្រិតកម្រៃចំពោះរដ្ឋហត្ថលេខីដែលមានការត្រួតពិនិត្យភាពថ្មី ។

៣. ចំនួន ទំហំ និងលក្ខណៈផ្សេងៗទៀតនៃ រូបថត ឬគំនូសតាងផ្សេងទៀតដែលជាតំណាងនៃគំនូរនីមួយៗដែលបានតម្កល់ ។

៤. ទំហំនៃសេចក្តីអធិប្បាយអំពីលក្ខណៈរូបរាងរបស់គំនូរ ។

៥. ការកម្រិត និងលក្ខខណ្ឌដែលសំណាក ឬ គំរូ នៃវត្ថុដែលមានបញ្ចូលគំនូរអាចអមជាមួយសំណុំលិខិតស្នើសុំ ។

៦. ចំនួននៃគំនូរដែលអាចបញ្ចូលក្នុងការតម្កល់ច្រើន និងលក្ខខណ្ឌផ្សេងទៀតដែលកំណត់ពីការតម្កល់ច្រើន ។

៧.គ្រប់បញ្ហាដែលពាក់ព័ន្ធនឹងការចុះផ្សាយនិងការចែកចាយព្រឹត្តិបត្រ ដែលបោះផ្សាយទៀងទាត់ដូចមានចែងក្នុងមាត្រា៦(៣)(ក) រួមបញ្ចូលទាំងចំនួននៃច្បាប់ចម្លងព្រឹត្តិបត្រដែលត្រូវផ្តល់ឱ្យទៅការិយាល័យជាតិដោយពុំគិតថ្លៃ ព្រមទាំងចំនួននៃច្បាប់ចម្លងដែលអាចលក់ទៅឱ្យការិយាល័យនេះដោយបញ្ចុះតំលៃ ។

៨. នីតិវិធីនៃការជូនដំណឹងដោយរដ្ឋហត្ថលេខី ចំពោះការបដិសេធណាមួយដូចមានចែងក្នុងមាត្រា៨(១) ព្រមទាំងនីតិវិធីដើម្បីជូនដំណឹងនិងចុះផ្សាយការ បដិសេធនេះដោយការិយាល័យអន្តរជាតិ ។

៩. លក្ខខណ្ឌដើម្បីធ្វើការកត់ត្រា និងការចុះផ្សាយដោយការិយាល័យអន្តរជាតិអំពីការផ្លាស់ប្តូរទាំងឡាយ ដែលប៉ះពាល់ដល់ម្ចាស់សិទ្ធិនៃគំនូរដូចមានចែងក្នុងមាត្រា១២(១) ព្រមទាំងលក្ខខណ្ឌដើម្បីបោះបង់សិទ្ធិដូចមានចែងក្នុងមាត្រា១៣ ។

១០. ការបោះបង់ចោលឯកសារ និងវត្ថុទាំងឡាយពាក់ព័ន្ធនឹងការតម្កល់ដែលលែងមានលទ្ធភាពក្នុងការចុះបញ្ជីសារឡើងវិញ។

## មាត្រា១៨

បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះមិនត្រូវរារាំងដល់ការទាមទារប្រយោជន៍ពីកិច្ចការពារច្រើនជាង ដែលអាចផ្តល់ដោយច្បាប់ជាតិនៃរដ្ឋហត្ថលេខីឡើយ ហើយ បទប្បញ្ញត្តិទាំងនេះក៏មិនប៉ះពាល់ដល់កិច្ចការពារ ដែលបានផ្តល់ចំពោះស្នាដៃសិល្បៈ និងស្នាដៃសិល្បៈអនុវត្តដោយសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ ។

## មាត្រា១៩ ដល់២២

[ ត្រូវបាននិរាករណ៍ដោយមាត្រា៧(២) នៃច្បាប់បន្ថែមទីក្រុងស្តុកហូម (១៩៦៧) ]

## មាត្រា២៣

១- កិច្ចព្រមព្រៀងនេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខារហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៦១ ។

២- កិច្ចព្រមព្រៀងត្រូវបានផ្តល់សច្ចាប័ន ហើយលិខិតតុបករណ៍នៃការផ្តល់សច្ចាប័នត្រូវតម្កល់ជាមួយនឹងរដ្ឋាភិបាលរបស់ប្រទេសហូឡង់ ។

## មាត្រា២៤

១- រដ្ឋទាំងឡាយដែលជាសមាជិកនៃសហភាពអន្តរជាតិ ទទួលបន្ទុកកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មដែលមិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ក៏អាចចូលជាសមាជិកបានដែរ ។

២- ការចូលជាសមាជិកនេះ ត្រូវជូនដំណឹងតាមរយៈបណ្តាញការទូតទៅកាន់អគ្គនាយក ហើយអគ្គនាយកត្រូវជូនដំណឹងទៅកាន់រដ្ឋាភិបាលរបស់រដ្ឋហត្ថលេខីទាំងអស់ ។

## មាត្រា២៥

១- រដ្ឋហត្ថលេខីនីមួយៗសន្យាថាការពារគំនូរឧស្សាហកម្ម និងចាត់វិធានការចាំបាច់នានាដើម្បីធានាការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ឱ្យស្របតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន ។

២- នៅពេលដែលរដ្ឋហត្ថលេខី តម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់ខ្លួន យោងតាមច្បាប់ជាតិរបស់ខ្លួន រដ្ឋនេះត្រូវផ្តល់អានុភាពដល់បទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា២៦

១- កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានក្នុងរយៈពេល១(មួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយក បានបញ្ជូនសេចក្តីជូនដំណឹងទៅរដ្ឋហត្ថលេខីអំពីការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកចំនួន១០(ដប់) ដោយយ៉ាងហោចណាស់មានលិខិតតុបករណ៍ចំនួនបួនក្នុងចំណោមលិខិតតុបករណ៍ទាំងនោះ គឺជារបស់រដ្ឋដែលនៅកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងនេះ មិនមែនជាភាគីនៃកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ឬមិនមែនជាភាគីកិច្ចព្រមព្រៀងឆ្នាំ ១៩៣៤។

២- បន្ទាប់មក ការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ននិងការចូលជាសមាជិក ត្រូវជូនដំណឹងទៅរដ្ឋហត្ថលេខីដោយអគ្គនាយក ។ ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកនេះត្រូវមានអានុភាព ក្នុងរយៈពេលមួយខែបន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនសេចក្តីជូនដំណឹង លើកលែងតែកាលបរិច្ឆេទក្រោយទៀតដែលបានកំណត់ក្នុងលិខិតតុបករណ៍នៃការចូលជាសមាជិក ក្នុងករណីចូលជាសមាជិក ។

## មាត្រា២៧

រដ្ឋហត្ថលេខីណាមួយអាចជូនដំណឹង នៅពេលណាក៏បានដល់អគ្គនាយក ថាកិច្ចព្រមព្រៀងនេះត្រូវអនុវត្តផងដែរចំពោះដែនដីទាំងមូល ឬមួយផ្នែកនៃដែនដីសម្រាប់ទំនាក់ទំនងខាងក្រៅ ដែលខ្លួនជាអ្នកទទួលខុសត្រូវ។ បន្ទាប់មក អគ្គនាយកត្រូវបញ្ជូនសេចក្តីជូនដំណឹងនេះទៅរដ្ឋហត្ថលេខី ហើយកិច្ចព្រមព្រៀងក៏ត្រូវអនុវត្តផងដែរចំពោះដែនដីដែលបានលើកឡើងខាងលើ ក្នុងរយៈពេលមួយខែបន្ទាប់ពីការបញ្ជូនការទំនាក់ទំនងដោយអគ្គនាយកទៅកាន់រដ្ឋហត្ថលេខី លើកលែងតែកាលបរិច្ឆេទក្រោយមកទៀតដែលបានបញ្ជាក់ក្នុងសេចក្តីជូនដំណឹង។

## មាត្រា២៨

១- តាមរយៈសេចក្តីជូនដំណឹងទៅអគ្គនាយក រដ្ឋហត្ថលេខីណាមួយអាចធ្វើការប្រកាសដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ ក្នុងនាមរដ្ឋខ្លួនផ្ទាល់ និងក្នុងនាមដែនដីទាំងមូល ឬមួយផ្នែកនៃដែនដីដែលបានជ្រើសរើសក្នុងសេចក្តីជូនដំណឹងតាមមាត្រា២៧ ។ សេចក្តីជូនដំណឹង

នេះត្រូវចូលជាធរមានក្នុងរយៈពេល១(មួយ) ឆ្នាំបន្ទាប់ពីអគ្គនាយកបានទទួលសេចក្តីជូនដំណឹងនេះ ។
២- ការប្រកាសដកខ្លួនចេញមិនត្រូវធ្វើឱ្យរដ្ឋហត្ថលេខីណាមួយលែងមានកាតព្វកិច្ចតាមកិច្ចព្រមព្រៀងនេះចំពោះគំនូរ ដែលបានតម្កល់នៅការិយាល័យអន្តរជាតិមុនកាលបរិច្ឆេទប្រកាសដកខ្លួនចេញចូលជាធរមាននោះទេ ។

## មាត្រា២៩

១- កិច្ចព្រមព្រៀងនេះត្រូវដាក់ដើម្បីកែប្រែ ក្នុងគោលបំណងធ្វើវិសោធនកម្មសំដៅពង្រឹងកិច្ចការពារដែលកើតចេញពីការតម្កល់គំនូរជាអន្តរជាតិ ។
២- សន្និសីទកែប្រែត្រូវកោះប្រជុំតាមការស្នើសុំ មិនតិចជាងពាក់កណ្តាលនៃរដ្ឋហត្ថលេខីទាំងអស់ ។

## មាត្រា៣០

១- លើកលែងលក្ខខណ្ឌទាំងឡាយដែលបានកំណត់ក្នុងសេចក្តីជូនដំណឹង រដ្ឋហត្ថលេខីពីរ ឬច្រើនអាចជូនដំណឹងដល់អគ្គនាយកនៅពេលណាក៏បានថា:

១. ការិយាល័យរួមមួយ ត្រូវជំនួសឱ្យការិយាល័យជាតិរបស់រដ្ឋហត្ថលេខីនីមួយៗ

២. រដ្ឋហត្ថលេខីពីរឬច្រើន ត្រូវចាត់ទុកជារដ្ឋតែមួយ ក្នុងគោលបំណងនៃការអនុវត្តមាត្រា២ដល់មាត្រា១៧ នៃកិច្ចព្រមព្រៀងនេះ ។

២- សេចក្តីជូនដំណឹងនេះ មិនត្រូវចូលជាធរមានរហូតដល់រយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកបានជូនដំណឹងអំពីបញ្ហានេះ ទៅកាន់រដ្ឋហត្ថលេខីផ្សេងទៀត ។

## មាត្រា៣១

១- កិច្ចព្រមព្រៀងតែមួយនេះត្រូវអនុវត្តចំពោះទំនាក់ទំនងទៅវិញទៅមកនៃ រដ្ឋដែលជាភាគីនៃកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ឬកិច្ចព្រមព្រៀង ឆ្នាំ១៩៣៤ ។ ប៉ុន្តែក្នុងទំនាក់ទំនងទៅវិញទៅមករបស់ខ្លួន រដ្ឋហត្ថលេខីទាំងនេះ ត្រូវអនុវត្តកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ឬ កិច្ចព្រមព្រៀងឆ្នាំ១៩៣៤ តាមករណីនីមួយៗ ចំពោះគំនូរដែលបានតម្កល់នៅ

ការិយាល័យអន្តរជាតិ មុនកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះ អាចអនុវត្តចំពោះទំនាក់ទំនងទៅវិញទៅមករបស់រដ្ឋហត្ថលេខីទាំងនេះ ។

២-

ក- រដ្ឋណាមួយដែលជាភាគីនៃកិច្ចព្រមព្រៀងនេះនិងកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ត្រូវបន្តអនុវត្តកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ក្នុងទំនាក់ទំនងជាមួយនឹងរដ្ឋដែលជាភាគីតែនៃកិច្ចព្រមព្រៀងឆ្នាំ១៩២៥ប៉ុណ្ណោះ លើកលែងតែរដ្ឋនោះបានប្រកាសដកខ្លួនចេញពីកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ។

ខ- រដ្ឋណាមួយដែលជាភាគីនៃកិច្ចព្រមព្រៀងនេះនិងកិច្ចព្រមព្រៀងឆ្នាំ១៩៣៤ ត្រូវបន្តអនុវត្តកិច្ចព្រមព្រៀងឆ្នាំ១៩៣៤ ក្នុងទំនាក់ទំនងជាមួយនឹងរដ្ឋដែលជាភាគីនៃកិច្ចព្រម ព្រៀងឆ្នាំ១៩៣៤ លើកលែងតែរដ្ឋនោះបានប្រកាសដកខ្លួន ចេញពីកិច្ចព្រមព្រៀងឆ្នាំ ១៩៣៤ ។

៣- រដ្ឋទាំងឡាយដែលគ្រាន់តែជាភាគីនៃកិច្ចព្រមព្រៀងនេះ មិនត្រូវចងភ្ជាប់ដោយរដ្ឋដែលជាភាគីនៃកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ឬកិច្ចព្រមព្រៀងឆ្នាំ១៩៣៤ ដោយមិនចាំបាច់ក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះទេ ។

## មាត្រា៣២

១- តាមកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងនេះ ការចុះហត្ថលេខានិងការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ដោយរដ្ឋណាមួយដែលជាភាគីនៃកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ឬ កិច្ចព្រមព្រៀងឆ្នាំ១៩៣៤ ត្រូវចាត់ទុកថាបានចុះហត្ថលេខានិង ផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃពិធីសារបន្ថែមចំពោះកិច្ចព្រមព្រៀងនេះ លើកលែងតែរដ្ឋនេះបានប្រកាសជាក់លាក់ផ្ទុយពីនេះ នៅពេលចុះហត្ថលេខា ឬតម្កល់លិខិតតុបករណ៍នៃការចូលជាសមាជិករបស់ខ្លួន ។

២- រដ្ឋហត្ថលេខីណាមួយដែលបានធ្វើសេចក្តីប្រកាសដូចមានចែងក្នុងកថាខណ្ឌ(១) ឬរដ្ឋហត្ថលេខីណាមួយផ្សេងទៀតដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងឆ្នាំ១៩២៥ ឬកិច្ចព្រមព្រៀងឆ្នាំ ១៩៣៤ អាចចុះហត្ថលេខា ឬចូលជាសមាជិកនៃពិធីសារដែលជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ។ នៅពេលចុះហត្ថលេខា ឬតម្កល់លិខិតតុបករណ៍នៃការចូលជាសមាជិករដ្ឋហត្ថលេខីអាចប្រកាសថា ខ្លួនមិនបានគិតថារដ្ឋខ្លួនត្រូវបានចងភ្ជាប់ដោយបទប្បញ្ញត្តិនៃកថាខណ្ឌ(២)(ក) ឬ (២)(ខ) នៃពិធីសារទេ ។ ក្នុងករណីនេះ រដ្ឋផ្សេងៗទៀតដែលជាភាគីនៃពិធីសារពុំមានកាតព្វកិច្ចដើម្បីអនុវត្ត ក្នុងទំនាក់ទំនងជាមួយរដ្ឋនោះ នូវបទប្បញ្ញត្តិដែល

បានលើកឡើងក្នុងសេចក្ដីប្រកាសឡើយ ។ បទប្បញ្ញត្តិនៃមាត្រា២៣ ដល់មាត្រា២៨ ត្រូវអនុវត្តដោយការប្រៀបធៀប ។

## មាត្រា៣៣

ច្បាប់នេះត្រូវចុះហត្ថលេខាជាអត្ថបទតែមួយច្បាប់ ដែលត្រូវយកទៅតម្កល់នៅក្នុងប័ណ្ណសារឋានរបស់រដ្ឋាភិបាលនៃប្រទេសហូឡង់ ។ អត្ថបទចម្លងមានការបញ្ជាក់ជាផ្លូវការត្រូវបញ្ជូនដោយរដ្ឋាភិបាលនៃប្រទេសហូឡង់ទៅកាន់រដ្ឋាភិបាលរបស់រដ្ឋនីមួយៗ ដែលបានចុះហត្ថលេខា ឬ ចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ។

## ពិធីសារ

រដ្ឋទាំងឡាយដែលជាភាគីនៃពិធីសារនេះបានព្រមព្រៀងដូចខាងក្រោមៈ

១- បទប្បញ្ញត្តិទាំងឡាយនៃពិធីសារនេះត្រូវអនុវត្តចំពោះគំនូរដែលជាកម្មវត្ថុនៃការតម្កល់ជាអន្តរជាតិ ហើយមានរដ្ឋណាមួយដែលជាភាគីនៃកិច្ចព្រមព្រៀងនេះត្រូវបានចាត់ទុកថាជារដ្ឋដើម ។

២- ចំពោះគំនូរទាំងឡាយដូចមានចែងក្នុងកថាខណ្ឌ(១) ខាងលើៈ

ក- រយៈពេលនៃកិច្ចការពារដែលបានផ្ដល់ឱ្យដោយរដ្ឋដែលជាភាគីនៃពិធីសារនេះចំពោះគំនូរដូចមានចែងក្នុងកថាខណ្ឌ(១) មិនត្រូវតិចជាង១៥(ដប់ប្រាំ) ឆ្នាំដោយគិតចាប់ពីកាលបរិច្ឆេទដែលបានចែងក្នុងកថាខណ្ឌ(១)(ក) ឬ(១)(ខ) តាមករណីនីមួយៗ នៃមាត្រា១១ ។

ខ- រូបរាងរបស់ កំណត់សម្គាល់លើវត្ថុទាំងឡាយដែលមានបញ្ចូលគំនូរ ឬលើស្លាកដែលភ្ជាប់នឹងវត្ថុនោះ ទោះករណីណាក៏ដោយ មិនត្រូវទាមទារដោយរដ្ឋជាភាគីនៃពិធីសារនេះទេ ទោះជាដើម្បីគោលបំណងប្រើប្រាស់ក្នុងដែនដីរបស់ខ្លួន នូវសិទ្ធិទាំងឡាយដែល កើតឡើងពីការតម្កល់ជាអន្តរជាតិក្នុងដែនដីរបស់រដ្ឋនោះ ឬក្នុងគោលបំណងណាមួយផ្សេងទៀតក៏ដោយ។